# ការណែនាំអំពី Medical Baseline Program

សូមស្វាគមន៍អំពីការណែនាំអំពី PG&E Medical Baseline Program។

កម្មវិធីនេះមានផ្តល់ជូនថាមពលនៅក្នុងតម្លៃទាបបំផុតសម្រាប់គម្រោងអត្រាបច្ចុប្បន្នរបស់អ្នក ប្រសិនបើអ្នកមានឧបករណ៍វេជ្ជសាស្ត្រដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នៅក្នុងផ្ទះរបស់អ្នក។ ឬស្ថានភាពជំងឺដែលមានតម្រូវការខាងកម្តៅ ឬត្រជាក់មួយចំនួន។ ដូច្នេះ អ្នកចំណាយប្រាក់តិចជាងមុនសម្រាប់ថាមពលដែលអ្នកត្រូវការ។

ឧទាហរណ៍នៃឧបករណ៍វេជ្ជសាស្ត្រដែលមានលក្ខណៈសម្បត្តិគ្រាប់គ្រាន់មួយចំនួនរួមមានដូចជា រទេះរុញដោយប្រើម៉ាស៊ីន ម៉ាស៊ីនជំនួយផ្លូវដង្ហើមពេលគេង (Continuous Positive Airway Pressure, CPAP) ឧបករណ៍ជំនួយការដកដង្ហើម និងម៉ាស៊ីនលាងឈាម។

ស្ថានភាពជំងឺដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មួយចំនួនរួមមានដូចជា ការពិបាកដកដង្ហើមពេលគេង ជំងឺក្រិនច្រើនកន្លែង ជំងឺស្លាប់មួយចំហៀងខ្លួន រោគខ្វិនអវយវៈទាំងបួន រោគស្លាប់ពាក់កណ្តាលខ្លួន និងជំងឺផ្សេងៗមួយចំនួនទៀតដែលមានតម្រូវការខាងកម្តៅ និងត្រជាក់។

ក្នុងអំឡុងពេលរដូវកាលភ្លើងឆេះព្រៃ ថាមពលអាចនឹងត្រូវផ្អាកដើម្បីហេតុផលសុវត្ថិភាព។ អតិថិជន Medical Baseline ទទួលការជូនដំណឹងបន្ថែមមុនពេលមាន Public Safety Power Shutoff។ ការជូនដំណឹងនេះផ្តល់ឱ្យអ្នកមានពេលវេលាបន្ថែម ដើម្បីត្រៀមខ្លួនមុនពេលការផ្តាច់ភ្លើង ដូច្នេះអ្នកអាចរក្សាសុវត្ថិភាពបាន។

ភាពមានសិទ្ធិទទួលបានគឺមិនអាស្រ័យទៅលើប្រាក់ចំណូលទេ គឺអាស្រ័យទៅលើតែតម្រូវការផ្នែកវេជ្ជសាស្ត្ររបស់អ្នកជំងឺនៅក្នុងផ្ទះប៉ុណ្ណោះ។

ការដាក់ពាក្យស្នើសុំតាមអនឡាញគឺជាជម្រើសដែលងាយស្រួលបំផុត ហើយចាប់ផ្តើមទទួលអត្ថប្រយោជន៍របស់អ្នកបានយ៉ាងឆាប់រហ័សបំផុត។

ដោយគ្រាន់តែអនុវត្តតាមជំហ៊ានទាំងនេះ៖

មួយ៖ បំពេញទម្រង់ពាក្យស្នើសុំតាមអនឡាញតាម pge.com/medicalbaseline។

ពីរ៖ អ្នកនឹងទទួលបានអ៊ីម៉ែលដែលមានលេខកូដបញ្ជាក់ និងសេចក្តីណែនាំពិសេសរបស់អ្នក។
ចែករំលែកលេខកូដនិងសេចក្តីណែនាំនោះជាមួយគ្រូពេទ្យដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ហើយពន្យល់គាត់ថាអ្នកត្រូវការជំនួយក្នុងការដាក់ពាក្យស្នើសុំរបស់អ្នក។

បី៖ គ្រូពេទ្យរបស់អ្នកនឹងប្រើលេខកូដពិសេសរបស់អ្នកដើម្បីបំពេញផ្នែករបស់គាត់។

បួន៖ នៅពេលដែលពាក្យសុំរបស់អ្នកត្រូវបានដំណើរការ អ្នកនឹងត្រូវបានចុះឈ្មោះចូលនៅក្នុងកម្មវិធី។ គម្រោងអត្រាអគ្គិសនីមួយចំនួនអាចនឹងត្រូវបានផាត់ចេញ។ ពិនិត្យមើលតាមអនឡាញតាមអាសយដ្ឋាន pge.com/medicalbaseline សម្រាប់ព័ត៌មានបន្ថែម។

អ្នកក៏អាចចូលទៅ pge.com/medicalbaseline ដើម្បីទាញយក និងបោះពុម្ពទម្រង់ពាក្យស្នើសុំជាក្រដាសដើម្បីបំពេញ រួចផ្ញើវាតាមប្រៃសណីយ៍មកយើងបានផងដែរ។
ឬហៅទូរសព្ទទៅលេខ 1-800-743-5000 និងស្នើសុំទម្រង់ពាក្យស្នើសុំជាក្រដាសជាអក្សរធំ ឬជាអក្សរសម្រាប់អ្នកពិការភ្នែកដែលត្រូវផ្ញើទៅអ្នក។
អ្នកតំណាងផ្នែកសេវាកម្មអតិថិជនអាចជួយអ្នកបានចំពោះសំណួរទាំងឡាយដែលអ្នកមាន។

យើងនៅទីនេះដើម្បីជួយ។ សូមអរគុណសម្រាប់ការសិក្សាស្វែងយល់អំពី Medical Baseline Program។